# សុវត្ថិភាពកៅអីរថយន្តសម្រាប់កុមារ

ចាប់ផ្ដើមដោយ
សុវត្ថិភាព

## បែរទៅក្រោយ



សម្រាប់ទារកដែលមានអាយុ
ប្រហែលអាយុ 30 ខែ

## បែរទៅមុខ



កៅអីនេះស័ក្តសមសម្រាប់
កុមារធំដែលអង្គុយមិនចុះ
កៅអីបែរទៅក្រោយ។

## ខ្សែក្រវាត់



កៅអីនេះលើកកុមារឡើង
ឲ្យត្រូវនឹងកម្ពស់ខ្សែក្រវាត់
សម្រាប់មនុស្សពេញវ័យ។

## ពង្រឹងសុវត្ថិភាព



ប្រើតេស្ត 5 ជំហានដើម្បី
ពិនិត្យមើល ថាតើកូនរបស់អ្នក
បានត្រៀមខ្លួនហើយឬនៅដើម្បី
ពាក់ខ្សែក្រវាត់កៅអី។

**វាជាការសំខាន់ដែលកុមារ មិនត្រូវរំកិលខ្លួនទៅរកកៅអីបន្ទាប់មុនពេលពួកគេត្រៀមខ្លួនពីព្រោះនេះអាច បង្កឲ្យមានរបួសធ្ងន់ធ្ងរ។ ប្រើសញ្ញាសម្គាល់ស្មានៅលើកៅអីរបស់អ្នកជានិច្ច ដើម្បីណែនាំអ្នក។**

ខ្សែគឺស្ថិតនៅត្រឹមស្មា។

ពិនិត្យមើលសញ្ញាសម្គាល់កម្ពស់អប្បបរមានិងអតិបរមាដែលមានទីតាំងនៅលើកៅអីកុមារ។

ធ្វើឱ្យប្រាកដថា ខ្សែមិនត្រូវបានរមួលចូលគ្នា និងឲ្យត្រូវនឹងទំហំប៉ុនម្រាមដៃមួយ។



ធានាថា ខ្សែក្រោយត្រូវបានភ្ជាប់ឲ្យជាប់នឹងគន្លឹះត្រឹមត្រូវ។

ដាក់កូនរបស់អ្នកដោយខ្នង និងគូថទល់នឹងកៅអីរថយន្ត។

ធានាថា ខ្សែក្រវ៉ាត់កៅអីមានសភាពតឹងដោយទប់កៅអីរថយន្តឱ្យនៅនឹងកន្លែង។

ពិនិត្យមើលថាខ្សែចងខាងលើត្រូវបានភ្ជាប់ទៅនឹងគន្លឹះ ហើយត្រូវបានទាញឲ្យតឹងដោយមិនធូរ/រលុង ហើយមិនមានរមួលចូលគ្នា

រកទីតាំងគន្លឹះទប់លំនឹងកុមារ ដែលបំពាក់ដោយរោងចក្រផលិតរថយន្ត (សូមមើលសៀវភៅណែនាំប្រើប្រាស់រថយន្តបើរកមិនឃើញ) និងបញ្ជាក់ថាអ្នកកំពុងប្រើគន្លឹះរបស់រថយន្តអ្នកឲ្យបានត្រឹមត្រូវ។

បង្ហាញដោយ ROAD SAFETY EDUCATION VICTORIA
Starting Out Safely
EARLY LEARNING ASSOCIATION AUSTRALIA
VICTORIA State Government

# សុវត្ថិភាពកៅអីរថយន្តសម្រាប់កុមារ

សម្រាប់កៅអី និងខ្នើយកៅអីទាំងអស់របស់កុមារ ខ្សែត្រូវតែត្រង់។ អ្នកប្រហែលជាត្រូវការខ្សែតដើម្បីឲ្យទៅដល់គន្លឹះ។

ចងចាំផងដែរថាត្រូវប្រើរបាររក្សាលំនឹងនៅពេលដែលកៅអីបែរទៅក្រោយ។

ប្រើខ្សែក្រវាត់កៅអី ឬឧបករណ៍ភ្ជាប់ Isofix។




ត្រូវប្រាកដថាអ្នកប្រើគន្លឹះឲ្យបានត្រឹមត្រូវសម្រាប់កៅអីកុមារ។

ទាំងនេះអាចរកឃើញនៅក្នុងបរិវេណដែលបង្ហាញតាមដ្យាក្រាមនេះ។ ប្រើសៀវភៅណែនាំប្រើប្រាស់រថយន្តរបស់អ្នកដើម្បីរកឱ្យបានត្រឹមត្រូវ។




ខ្សែចងខាងក្រោម និងគន្លឹះខាងក្រោម ដូចដែលបានបង្ហាញ ត្រូវបានប្រើ**តែ**នៅក្នុងកៅអីរថយន្តដែលបំពាក់ជាមួយឧបករណ៍ភ្ជាប់ ISOFIX ប៉ុណ្ណោះ។



ត្រូវប្រាកដថាកៅអីនោះមានបិទស្ទីគ័រស្តង់ដាអូស្រ្តាលីដែលបានអនុម័ត និងបិទស្លាកបង្ហាញលេខកូដ **AS/NZS 1754**។ ស្ទីគ័រ**មិន**ត្រូវខូច ឬបកចេញទេ។ មិនត្រូវប្រើកៅអីដែលគ្មានបិទស្ទីគ័រត្រឹមត្រូវឡើយ។




មុនពេលផ្លាស់ទីកុមារពីកៅអីពង្រឹងសុវត្ថិភាព **សូមធានាថាបំពេញគ្រប់ជំហានទាំង 5 នៃលក្ខខណ្ឌធ្វើតេស្ត។**

ប្រសិនបើមិនបានបំពេញគ្រប់ជំហានទាំង 5 ទេ កុមារត្រូវតែបន្តអង្គុយនៅក្នុងកៅអីពង្រឹងសុវត្ថិភាព។

នេះប្រហែលជា 145cm

**តេស្តប្រាំជំហាន**




កន្លែងដែលមានសុវត្ថិភាពបំផុតសម្រាប់កុមារអង្គុយគឺស្ថិតនៅកៅអីក្រោយ។ ក្មេងចាប់ពីអាយុ 12 ឆ្នាំឡើងមានកម្ពស់ចាប់ពី 145cm ឡើងអាចអង្គុយនៅកៅអីខាងមុខបាន។

ហាមដាក់កៅអីបែរទៅខាងក្រោយនៅកន្លែងមានបំពាក់ពោងសុវត្ថិភាព។



ចំពោះព័ត៍មានបន្ថែមសូមចូលទៅកាន់គេហទំព័រចាប់ផ្តើមដោយសុវត្ថិភាពរបស់ ELAA www.childroadsafety.org.au